ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានឯកអគ្គរាជទូតកម្ពុជា
ប្រចាំប្រទេសជប៉ុន

សូមគោរពជូន

ឯកឧត្តម ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីពាណិជ្ជកម្ម

**<u>កម្មវត្ថុៈ</u>** របាយការណ៍ស្តីពី កិច្ចប្រជុំ ជប៉ុន-មេកុងលើកទី ២ នៅក្រុងតូក្យូ ។

ខ្ញុំបាទមានកិត្តិយសសូមរាយការណ៍ជូន **ឯកឧត្តម** មេត្តាជ្រាបថា កាលពីថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ ២០១១ ខ្ញុំបានចូលរួមក្នុងកិច្ចប្រជុំខាងលើនៅសាលប្រជុំមីតាក្រុងតូក្យូ ។ កម្មវិធីនេះរៀបចំដោយក្រសួងការបរទេសជប៉ុន សហការជាមួយវិស័យឯកជន ។ សមាសភាពចូលរួមមានអ្នកតំណាងខាងរដ្ឋាភិបាលនិងវិស័យឯកជន ចំនួន១៣ នាក់ (ក្នុងនោះមានយុវមន្ត្រី ១០ នាក់ មកពីអន្តរក្រសួង នៃកម្មវិធី JENESYS- Japan East Asia Network of Exchange for Student and Youths ក៏បានចូលរួមអង្គប្រជុំនេះដែរ) របស់ប្រទេសជាសមាជិកនិមួយៗនៃប្រទេសមេកុងទាំងប្រាំ( កម្ពុជា-ឡាវ -មីយ៉ាន់ម៉ា-ថៃ-វៀតណាម) និងប្រទេសជប៉ុន ។

សម័យប្រជុំមានគោលបំណង លើកឡើងពីការសន្យារបស់ប្រទេសជប៉ុន ដើម្បីពង្រឹងទំនាក់ទំនងរវាងប្រទេសមេកុងនិងជប៉ុននាថ្ងៃមុខ ។ អង្គប្រជុំបានស្តាប់មតិប្តូរបទពិសោធន៍ទៅវិញទៅមករវាងអ្នកតំណាងរដ្ឋាភិបាល យុវមន្ត្រី និងការពិភាក្សាផ្ទាល់ជាមួយវិស័យឯកជនលើគំរោងជាក់ស្តែង ។

កម្មវិធីលំអិតមានដូចខាងក្រោមៈ

**១- វគ្គទី ១:** ពិធីបើកសម័យប្រជុំប្រារព្ធឡើងដោយលោក Ryuji Yamane អនុរដ្ឋមន្ត្រីការបរទេសជប៉ុន លោកបានថ្លែងទាក់ទងការលើកស្ទួយកំណើនសេដ្ឋកិច្ចនៅប្រទេសតំបន់មេកុង យោងតាមសេចក្តីប្រកាសតូក្យូ- Tokyo Declaration និងផែនការសកម្មភាព ៦៣ ដែលបានអនុម័តឡើងកាលពីកិច្ចប្រជុំកំពូល មេកុង-ជប៉ុន លើកទី ១ ក្នុងឆ្នាំ ២០០៩ ការស្តារហេដ្ឋារចនាសម្ព័ន្ធ នៅតំបន់បូពាំប្រទេសជប៉ុនដែលរងអន្តរាយដោយគ្រោះធម្មជាតិ និងបញ្ហាទឹកជំនន់នៅតំបន់មេកុង ។

អ្នកតំណាងវិស័យឯកជនជប៉ុន មានទស្សនៈថា ប្រទេសក្នុងតំបន់មេកុង នឹងក្លាយជាដៃគូរសំខាន់សំរាប់ក្រុមហ៊ុនជប៉ុន ហើយមានលទ្ធភាពជំរុញកិច្ចសហការរវាងវិស័យសាធារណៈនិងឯកជន ។ បន្តមកមានបទអន្តរាគមន៍របស់អ្នកតំណាងប្រទេសទាំងប្រាំ ពាក់ព័ន្ធស្ថានភាពទូទៅនៃប្រទេសទាំងនោះ ។

*8-6-9 AKASAKA, MINATO-KU, TOKYO 107-0052* *Tel: (81 3)5412-8521 Fax: (81 3)5412-8526*
*E-mail : camembassyjp@gmail.com*

**២-វគ្គទី ២:** ទាក់ទងបទឱទ្ទេសនាម របស់ប្រទេសកម្ពុជា- ឡាវ និងមីយ៉ាន់ម៉ា លើវិស័យវិនិយោគ និងការចាប់អារម្មណ៍របស់អ្នកតំណាងសហព័ន្ធពាណិជ្ជកម្មជប៉ុន ពាក់ព័ន្ធវិធានការ និងផែនការពង្រឹងទំនាក់ទំនងសេដ្ឋកិច្ច ជាមួយប្រទេសក្នុងតំបន់មេកុង។

**៣-វគ្គទី៣:** ចែកជាក្រុមពិភាក្សាចំនួនបី:

**ក-** Enhancing ASEAN Connectivity: ជប៉ុនផ្តោតអារម្មណ៍លើការជំរុញច្រករបៀងសេដ្ឋកិច្ច ការអភិវឌ្ឍន៍ធនធានមនុស្ស ការដឹកជញ្ជូនទំនិញឆ្លងដែន ភាពងាយស្រួលក្នុងការបំពេញបែបបទឆ្លងដែន និងកិច្ចសហការវិស័យសាធារណៈនិងឯកជន។

**ខ-**មេរៀន និងវិធានការ បានមកពីការខិតខំស្តារដំណើរការផលិតកម្មឡើងវិញ របស់ក្រុមហ៊ុនជប៉ុននៅតំបន់បូព៌ាប្រទេស និងកិច្ចសហការការពារគ្រោះធម្មជាតិរវាងជប៉ុន- មេកុង ទៅថ្ងៃអនាគត។

**គ-**ការរៀបចំបញ្ហាបរិដ្ឋាននៅទីក្រុងឱ្យបានប្រសើរ- ការគ្រប់គ្រងប្រភពទឹក-ថាមពល។

អង្គប្រជុំបានថ្លែងអំណរគុណ ដល់រដ្ឋាភិបាល និងប្រជាជនជប៉ុន នូវរាល់កិច្ចខំប្រឹងប្រែងដើម្បីបន្តកិច្ចសហប្រតិបត្តិការរវាងវិស័យសាធារណៈនិងឯកជនក្នុងតំបន់មេកុង នឹងនាំមកនូវបរិយាកាសវិនិយោគឱ្យបានប្រសើរ ពង្រឹងនិងធានា ភាពរីកចំរើនសេដ្ឋកិច្ចក្នុងតំបន់ ដូចនេះក្រុមហ៊ុនជប៉ុននឹងដើរតួរសំខាន់ក្នុងការទ្រទ្រង់ខ្សែសង្វាក់ផ្គត់ផ្គង់ឧស្សាហកម្ម ក្នុងតំបន់មេកុង។

អាស្រ័យហេតុនេះសូម **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍។

សូម **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

តូក្យូ ថ្ងៃ ទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១១

លឹម ធារិទ្ធ